ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រង
# តំបន់ការពារធម្មជាតិ/កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់

## រយៈពេល ០៣ឆ្នាំ
## ២០១៩-២០២១

| | | |
|---|---|---|
| កន្លែងនេសាទសហគមន៍ | ៖ | អន្លង់ត្រីស្រែខ្សាច់ |
| ភូមិ | ៖ | ស្រែខ្សាច់ |
| ឃុំ | ៖ | ដងកាំបិត |
| ស្រុក | ៖ | សណ្ដាន់ |
| ខេត្ត | ៖ | កំពង់ធំ |

# មាតិកា


១.ស្ថានភាពទូទៅ ..... ១

២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..... ២

ក.ប្រជាពលរដ្ឋ ..... ២

ខ. មុខរបរ ..... ២

៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ..... ៣

ក. ទីតាំង ..... ៣

ខ. ដែននេសាទ ..... ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ..... ៤

ឃ. ធនធានជលផល ..... ៤

១.ប្រភេទត្រី ..... ៤

២.ប្រភេទវារីសត្វ ..... ៤

៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ..... ៤

៤.ការធ្វើនេសាទ ..... ៤

ក.អ្នកនេសាទ ..... ៥

ខ.ឧបករណ៏នេសាទ ..... ៥

គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ ..... ៦

៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៧

ក.ទស្សនៈវិស័យ ..... ៧

ខ.គោលបំណង ..... ៧

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៧

គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ..... ៧

គ.២. ផែនការកែលម្អដែននេសាទ ..... ៧

គ.៣. ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ..... ៨

គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ..... ៩

គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ..... ៩

គ.៦.ផែនការថវិកាទ្រទ្រង់សម្រាប់ការអភិវឌ្ឍន៍សហគមន៍នេសាទ ..... ១០

គ.៧.ផែនការចុះល្បាត ..... ១០

គ.៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ..... ១០

គ.៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ ..... ១១

គ.១០. ផែនការជួសជុលស្នាក់ការសហគមន៍នេសាទ ..... ១១

គ.១១. ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ ..... ១២

គ.១២. ផែនការបង្កើតក្រុមសន្សំ ..... ១២

គ.១៣. ផែនការបង្កើតមុខរបរទ្រទ្រង់ជីវភាពសហគមន៍នេសាទ ..... ១៣

គ.១៤. ផែនការទឹកស្អាត ..... ១៣

ឃ. យុទ្ធសាស្រ្ត ..... ១៤
៦.ឧបសម្ពន្ធ
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៩-២០២១ ..... ១៥
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៩-២០២១ ..... ១៨

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់

**១.ស្ថានភាពទូទៅ**

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ ដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផល នៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព សមភាព និងសមធម៌ តាមបែបសហគមន៍នេសាទ ក្នុងគោលបំណង ទទួលបានផលប្រយោជន៍ និងធ្វើអោយធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។

សហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** មានទីតាំងស្ថិតនៅក្នុងភូមិស្រែវាលលិច និងស្រែវាលកើត, ឃុំដងកាំបិត ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន ៨៦នាក់ ស្រីមានចំនួន ២០នាក់ និងមានគណៈកម្មការ ចំនួន ០៧នាក់ ស្រីមានចំនួន ០២នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន ៧៤គ្រួសារ។

សហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតដំបូងនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០។

កន្លងមកសហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន៖

- ផ្សព្វផ្សាយបង្កើនការយល់ដឹង អំពីទស្សនទានសហគមន៍នេសាទដល់ប្រជាពលរដ្ឋក្នុងភូមិ
- ចុះបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- បង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- កំណត់ព្រំប្រទល់ និងគូសផែនទីកន្លែងនេសាទសហគមន៍
- បោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួន០៨បង្គោល
- ដាក់ស្លាកសញ្ញាសំគាល់កន្លែងអន្លង់អភិរក្ស ចំនួន០៤ស្លាក
- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលកំពង់ធំ (២៩ កក្កដា ២០១០)
- ធ្វើស្លាកផ្ទាំងធំ ចំនួន០២ផ្ទាំង
- ធ្វើកាណូត ចំនួន០១គ្រឿង
- បានពិភាក្សារៀបចំធ្វើសេចក្តីព្រាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ក្នុងរយៈពេល ៣ឆ្នាំ
- បានរៀបចំវគ្គផ្សព្វផ្សាយស្តីពីសារៈប្រយោជន៍នៃការគ្រប់គ្រងធនធានជលផលដល់សមាជិកសហគមន៍
- ផ្សព្វផ្សាយច្បាប់អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងច្បាប់ជលផលស្តីពីជលផលនៅកម្ពុជា
- ចុះយាមល្បាតកន្លែងនេសាទសហគមន៍
- ប្រជុំប្រចាំខែក្នុងសហគមន៍នេសាទ
- បានចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ
- បានចូលរួមធ្វើកម្មវិធីវិនិយោគឃុំ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមានចំនួន៣៣៩នាក់ ប្រុស១៧៧នាក់ ស្រី១៦២នាក់
- ក្នុងនោះមានជនជាតិខ្មែរចំនួន១០០%
- ចំនួនស្ត្រីមេម៉ាយសរុបក្នុងសហគមន៍នេសាទមានចំនួន ០៧នាក់
- ចំនួនជនពិការសរុបក្នុងសហគមន៍នេសាទមានចំនួន **០៦**នាក់ ប្រុស០៤នាក់ ស្រី០២នាក់
- ចំនួនចាស់ជរាសរុបក្នុងសហគមន៍នេសាទមានចំនួន ០៨នាក់ ប្រុស០៣នាក់ ស្រី០៥នាក់
- ចំនួនកុមារកំព្រាសរុបក្នុងសហគមន៍នេសាទមាន ០៥នាក់ ប្រុស០២នាក់ ស្រី០៣នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃសរុបក្នុងសហគមន៍នេសាទមាន ០៣នាក់ ប្រុស០២នាក់ ស្រី០១នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់

- អ្នកមិនចេះអក្សរមានចំនួន ៦០នាក់ ប្រុស៤៥នាក់ ស្រី១៥នាក់
- កម្រិតថ្នាក់បឋមសិក្សាមានចំនួន ២៥នាក់ ប្រុស២០នាក់ ស្រី០៥នាក់
- កម្រិតថ្នាក់មធ្យមសិក្សាមានចំនួន ០១នាក់ ប្រុស០១នាក់ ស្រី០០នាក់
- កម្រិតថ្នាក់ឧត្តមសិក្សាមានចំនួន ០០នាក់ ប្រុស០០នាក់ ស្រី០០នាក់។

### ខ. មុខរបរ

តាមរបាយការណ៍ និងឯកសារឃុំ បានបញ្ជាក់ថានៅក្នុងសហគមន៍អន្លង់ត្រីស្រែខ្សាច់ មានប្រពលរដ្ឋសរុបចំនួន១៧១ គ្រួសារដែលពឹងផ្អែកលើការនេសាទនិងការចិញ្ចឹមត្រី រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជាធ្វើស្រែចំការ ដាំបន្លែ និងលក់ដូរជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបង ដែលជួយពង្រីកមុខរបរដល់ប្រជានេសាទ នៅក្នុងសហគមន៍ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើ ធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផលនិងអង្គការដៃគូអភិវឌ្ឍន៍ បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេស ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន ពេលបច្ចុប្បន្នក្នុងសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ប្រជាពលរដ្ឋមានមុខរបរសំខាន់ៗដូចជា៖

#### ខ.១. អ្នកដែលមានមុខរបរនេសាទ

- ធ្វើនេសាទមានចំនួន ១៩០គ្រួសារ
- អ្នកកែច្នៃផលត្រី និងនេសាទដូចជា ធ្វើផ្អក ប្រហុក និងត្រីឆ្អើរ មានចំនួន ១៩០គ្រួសារ (ជាលក្ខណៈគ្រួសារ)។

#### ខ.២. អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ

- ធ្វើស្រែមានចំនួន ៣៥ គ្រួសារ ទំហំ ៣៧៤ហិកតា
- ធ្វើចំការមានចំនួន ៧១ គ្រួសារ ទំហំ ៦៥០ហិកតា
- ដាំបន្លែមានចំនួន ៧៤ គ្រួសារ
- ជាងផ្ទះមានចំនួន ០៤ គ្រួសារ
- លក់ដូរមានចំនួន ០៧ គ្រួសារ
- ឡើងត្នោតមានចំនួន ០២ គ្រួសារ

- ចិញ្ចឹមសត្វមានចំនួន ៨៦ គ្រួសារ
- ពេទ្យសត្វមានចំនួន ០២ គ្រួសារ
- ម៉ាស៊ីនកិនស្រូវមានចំនួន១៦ គ្រួសារ
- ឆ្មបបុរាណមានចំនួន ០៤ គ្រួសារ
- អ្នកស្ម័គ្រចិត្តសុខភាពភូមិមានចំនួន ០៤ គ្រួសារ
- អ្នកស្ម័គ្រចិត្តជំងឺគ្រុនចាញ់ភូមិមានចំនួន ០៤ គ្រួសារ
- ម៉ាស៊ីនបោកស្រូវមានចំនួន ០៥ គ្រួសារ
- ជាងធ្វើម៉ាស៊ីនកាណូតមានចំនួន ០២ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងសហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** មានទីតាំងស្ថិតនៅក្នុងភូមិស្រែវាលលិច ស្រែវាលកើត ឃុំដងកាំបិត ស្រុកសណ្ដាន់ ជាដែននេសាទទឹកសាបតាមដងស្ទឹងសែន ប៉ែកខាងជើងនៃខេត្តកំពង់ធំ (អន្លង់ត្រីតាមដង ស្ទឹងសែន)។

កន្លែងសហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** មានទំហំ៣៣ហិកតា ហើយមានអន្លង់ចំនួន០៦អន្លង់និងអូរចំនួន០២។ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួល ស្គាល់ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។

កន្លែងនេសាទសហគមន៍**អន្លង់ត្រីស្រែខ្សាច់** មានព្រំប្រទល់ជាប់នឹង ៖

- ខាងជើងទល់ នឹងអូរគគីរធំ (ចំនុចអូរដារ)
- ខាងត្បូងទល់ នឹងតំបន់ឬស្សីស្រុក(ចំនុចអន្លង់បេង)
- ខាងកើតទល់ នឹងមាត់ច្រាំងស្ទឹង
- ខាងលិចទល់ នឹងមាត់ច្រាំងស្ទឹង។

### ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** មានទំហំ៣៣ហិកតា មានអន្លង់ចំនួន០៥អន្លង់ និងអូរចំនួន០៦ ដែលបាន គ្របដណ្ដប់លើកន្លែងនេសាទសហគមន៍

| | | |
|---|---|---|
| - អន្លង់ជួរត្នោត | មានទំហំ ៣០ម x ២០ម | នេសាទពីខែវិច្ឆិកា ដល់ ខែឧសភា |
| - អន្លង់តាំងយូរ | មានទំហំ ៦០ម x ២០ម | ជាកន្លែងអភិរក្ស |
| - អន្លង់តាំងគត | មានទំហំ ៥០ម x ៦០ម | ជាកន្លែងអភិរក្ស |
| - អន្លង់សៀមហាយ | មានទំហំ ៦០ម x ៨០ម | ជាកន្លែងអភិរក្ស |
| - អន្លង់ជួរវែង ឬ ជួរថ្មី | មានទំហំ ៦០ម x ១០០ម | នេសាទពីខែវិច្ឆិកា ដល់ ខែឧសភា |
| - អូរស្រែចារ | មានទំហំ ៤ម x ៤៥០ម | នេសាទពីខែសីហា ដល់ ខែធ្នូ |
| - អូរតាង៉ុត | មានទំហំ ៧ម x ១៥០០ម | នេសាទពីខែសីហា ដល់ ខែធ្នូ |
| - អូរកូនត្នោត | មានទំហំ ៧ម x ៦០០០ម | នេសាទពីខែសីហា ដល់ ខែធ្នូ |
| - អូរឬស្សី | មានទំហំ ៤ម x ២០០០ម | នេសាទពីខែសីហា ដល់ ខែធ្នូ |
| - អូរគគីរតូច | មានទំហំ ៧០ម x ៤០០០ម | នេសាទពីខែសីហា ដល់ ខែធ្នូ |
| - អូរគគីរធំ | មានទំហំ ១០ម x ៦០០០ម | នេសាទពីខែសីហា ដល់ ខែធ្នូ |

- ព្រៃលិចទឹកតាមមាត់អូរ មានទំហំ ៦ហិកតា

## ៣. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់ បង្កើតកន្លែងអភិរក្សចំនួន០៣កន្លែង ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ។ កន្លែងអភិរក្សត្រីមេពូជត្រូវបានធ្វើការគ្រប់គ្រងដោយសហគមន៍នេសាទមានដូចជា៖

| ល.រ | ឈ្មោះតំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស | ទំហំជាហិកតា | ប្រវែង | ជម្រៅ |
|---|---|---|---|---|
| ០១ | អន្លង់តាំងយូរ | ០,១២ | ១០០ម x ៦០ម | ៤ម |
| ០២ | អន្លង់សៀមហាយ | ០,៤៨ | ៦០ម x ២០ម | ៦ម |
| ០៣ | អន្លង់តាំងគត់ | ០,៣ | ៥០ម x ៦០ម | ៨ម |

## ឃ. ធនធានជលផល

នៅប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយខ្សែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ និងអាចរកប្រាក់ចំណូលពីការលក់ដូរផលនេសាទ ហើយនៅពេលដែលរដូវត្រីប្រហុក មកដល់ប្រជាជនតែងតែនាំគ្នាធ្វើប្រហុកផ្អកសម្រាប់បរិភោគ និងលក់បានមួយចំនួន។

### ឃ.១. ប្រភេទត្រី

កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់ មានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍គុក ត្រីក្អែក ត្រីគ្រុំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ត្រប់ ត្រីប្រម៉ា ត្រីគ្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្នឹង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្ពោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីជីវី ត្រីកំផ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្ទៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្នាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីក្អែក ត្រីលិញ ។ល។

### ឃ.២. ប្រភេទវារីសត្វ

កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់ មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង់ កេ សត្វស្វាក្រះ សំពោច ។ល។

### ឃ.៣. ប្រភេទបក្សី

កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់ មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទោម សត្វទុង សត្វប្រវីក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វទុង សត្វស្មោញ សត្វសេក សត្វលលក សត្វចាប សត្វត្រយង សត្វនាលខ្យង សត្វក្រដក់ សត្វក្រសា សត្វកំពឹងដួង។ល។

### ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

កន្លែងនេសាទសហគមន៍អន្លង់ត្រីស្រែខ្សាច់ មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើម តាអូរ ដើមអញ្ចាញ ដើមថ្វាន់ ដើមកន្សែង ដើមបន្លាយូន ដើមស្វាចទឹក ដើមកណ្តាប់ចង្អេរ ដើមរំដេញ ដើមបន្លាស្អិត។ល។

## ៤. ការធ្វើនេសាទ

ការធ្វើនេសាទជាមុខរបរចាំបាច់ សម្រាប់ការចិញ្ចឹមជីវិតរបស់សមាជិកសហគន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ផលិតផលត្រីត្រូវបានធ្វើអាជីវកម្មក្នុងតំបន់ផ្ទាល់ដើម្បីរកចំណូលពេលបច្ចុប្បន្នប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍ អន្លង់ត្រីស្រែខ្សាច់ បានផ្តោតលើការនេសាទដោយបានប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារក្នុងការទាញយកផលនេសាទប៉ុន្តែ[illegible] របស់សមាជិកសហគមន៍ និងអ្នកខាងក្រៅត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទី[illegible] ផែនការគ្រប់គ្រងរបស់សហគមន៍នេសាទដែលបានរៀបចំសម្រាប់ឆ្នាំ២០១៨ដល់ឆ្នាំ២០២០។

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៣១២នាក់ ស្រីមានចំនួន ១៧៨នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍មានចំនួន ៧២០នាក់ ស្រីមានចំនួន ៣៤៨នាក់
- តាមការប៉ាន់ស្មានអ្នកនេសាទ ដែលមកពីខាងក្រៅហើយមិនមែនជាសមាជិកសហគមន៍មានប្រហែល០៨នាក់ ស្រី០៣នាក់ ក្នុង១ឆ្នាំនៅក្នុងកន្លែងនេសាទសហគមន៍ អន្លង់ត្រីស្រែខ្សាច់ ។

**ខ. ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទប្រជាជននៅក្នុងសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ និងអ្នកខាងក្រៅ តែងតែធ្វើនេសាទ ដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារ ដូចជា លប មង សន្ទូច លបព្រៀង ឡើ លាន់ និងដុច។ល។ សមាជិក និងគណៈកម្មការសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ បានធ្វើការប៉ាន់ប្រមាណពីតម្រូវ ការប្រភេទឧបករណ៍ ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេសសមាជិក និងគណៈកម្មការសហគមន៍នេសាទ បានស្នើសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ នេសាទនិងអ្នកនេសាទមកពីខាងក្រៅ លើប្រភេទឧបករណ៍នេសាទ ដែល ហាមឃាត់ដូចជា ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង គ្រាប់បែក។ល។

**ឧបករណ៍នេសាទ ទូក និងកាណូត របស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍ដូចជា៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ(៤០ម) | ៤០ម x ៧១ដៃ | ៣-៩ហ៊ុន x ២.៥ម x ២៨៤០ម | ខែវិច្ឆិកា ដល់ ឧសភា |
| ០២ | សំណាញ់ | វង់ | ៣៥នាក់x ១ | ៣-៤ហ៊ុន x ១២ហាត់ | ខែវិច្ឆិកា ដល់ ខែមិថុនា |
| ០៣ | សន្ទូច | ផ្លែ | ១សាង=១០០ | ៩០០ផ្លែ លេខ១២-១៥ | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៤ | លប | គ្រឿង | ១នាក់ x ២ | ០,៦ម x ១,៦ម x ៣សម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៥ | ប៉ោង | គ្រឿង | ២នាក់ x ១ | ០,៤០ម x ១,៣០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៦ | ចាន់ | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,២០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៧ | ទ្រូ | គ្រឿង | ៦៥នាក់ x ២ | ០,៦០ម x ១,២០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៨ | តុំឬកន្សុំ | គ្រឿង | ២៥នាក់ x ២ | ២,៥-៤ហ៊ុន x ៦ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៩ | សៃយ៉ឺន | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,៥០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១០ | បង្គៃ | ផ្លែ | ៣នាក់ x ១០០ | លេខ៧-១០ | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១១ | ឈ្នាង | គ្រឿង | ២នាក់ x ១ | ០,៦០ម x ១,២០ម | ខែធ្នូ ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនតូច | ១៥០ | ៥០០ - ១តោន | |
| ទូកអុំ | ១០០ | ១០០ | |

**ឧបករណ៍នេសាទ ទូក និងកាណូត របស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ដែលប្រើប្រាស់៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ(៤០ម) | ៤០ម x ៧១ដៃ | ៣-៩ហ៊ុន x ២.៥ម x ២៨៤០ម | មួយឆ្នាំពេញ |
| ០២ | សំណាញ់ | វង់ | ៣៥នាក់ x ១ | ៣-៤ហ៊ុន x ១២ហាត់ | មួយឆ្នាំពេញ |
| ០៣ | សន្ទូច | ផ្លែ | ១សាង=១០០ | ៩០០ផ្លែ លេខ១២-១៥ | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៤ | លប | គ្រឿង | ១នាក់ x ២ | ០,៦ម x ១,៦ម x ៣សម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៥ | រ៉ោង | គ្រឿង | ២នាក់ x ១ | ០,៤០ម x ១,៣០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៦ | ចាន់ | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,២០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៧ | ទ្រូ | គ្រឿង | ៦៥នាក់ x ២ | ០,៦០ម x ១,២០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៨ | តុំឬកន្សំ | គ្រឿង | ២៥នាក់ x ២ | ២,៥-៤ហ៊ុន x ៦ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៩ | សៃយឺន | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,៥០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១០ | បង្កៃ | ផ្លែ | ៣នាក់ x ១០០ | លេខ៧-១០ | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១១ | ឈ្នាង | គ្រឿង | ២នាក់ x ១ | ០,៦០ម x១,២០ម | ខែធ្នូ ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ១៥ | ៣០០ - ៥០០ | ៦ ដល់ ១៨ |
| កាណូតម៉ាស៊ីនតូច | ៤៨ | ៥០០ - ១តោន | ៦ |
| ទូកអុំ | ៥០ | ១០០ | |

**ឧបករណ៍នេសាទ ទូក និងកាណូត របស់អ្នកមិនមែនជាសមាជិកសហគមន៍នេសាទដែលមកពីខាងក្រៅ៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ(៥០ម) | ៥០ម x១០ដៃ | ៤-៩ហ៊ុន x ២.៥ម | មួយឆ្នាំពេញ |
| ០២ | បង្កៃ | ផ្លែ(១០០) | ១០នាក់ x ៥០ | លេខ៧-៩ | មួយឆ្នាំពេញ |
| ០៣ | សន្ទូចនេង | ផ្លែ(១០០) | ១០សាង=១០០ | លេខ១៤-១៦ | មួយឆ្នាំពេញ |
| ០៤ | សំណាញ់ | វង់ | ១០នាក់ x ១ | ៣-៤ហ៊ុន x ១២ហាត់ | មួយឆ្នាំពេញ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ **Kubuta** | ២៥ | ៣០០ - ៥០០ | ៦ ដល់ ១៨ |
| កាណូតម៉ាស៊ីនតូច | ៣២ | ៥០០ - ១តោន | ៦ |
| ទូកអុំ | ០០ | ០០ | |

## គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ២,០០០ | ១,៥០០ | ៣,៥០០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ១០ | ៥០ | [illegible] |
| អន្ទង់ | ០០ | ០០ | [illegible] |
| **សរុប** | **២,០១០** | **១,៥៥០** | **៣,៥៦០** |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធម៌ និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនន់ឡើងព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងជានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ នេសាទតាមរយៈ ការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយបាន គិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុក ដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទ លើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទ អន្លង់ត្រីស្រែខ្សាច់ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖**

| ឈ្មោះកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើកន្លែងនេសាទសហគមន៍ | | | |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | ផ្សេងៗ |
| អន្លង់ដូរគ្រោត | ១ឆ្នាំពេញ | មង | ក្រឡា= ៤-៥ហ៊ុន<br>សម្រុង= ២,៥ហ៊ុនx១៥០ម | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០ម |
| | | សំណាញ់ | ក្រឡា= ៣-៤ហ៊ុន<br>ប្រវែង=១២ហាត់ | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១ដំ |
| អន្លង់អន្លង់ដូរវែង | ១ឆ្នាំពេញ | មង | ក្រឡា= ៤-៥ហ៊ុន<br>សម្រុង= ២,៥ហ៊ុនx៥០ម | ៣នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០ម |
| | | សំណាញ់ | ក្រឡា= ៣-៤ហ៊ុន<br>ប្រវែង=១២ហាត់ | ៣នាក់ ក្នុង១ថ្ងៃ | ១នាក់=១ដំ |

### គ.២. ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថាដែននេសាទនៅក្នុងសហគមន៍នេសាទ អន្លង់ត្រីស្រែខ្សាច់ មានសភាពប្រែប្រួលខ្លះ ដែលបណ្តាល មកពីកត្តាមនុស្ស និងធម្មជាតិ ដូចជាព្រែកដែលធ្វើចរាចរទទួលរងការរាក់ដែលបណ្តាលមកពីការដាក់ក្នុងអួរ និងការហូរច្រោះដោយសារការកាប់ទន្រ្ទាញព្រៃលិចទឹកនៅតាមមាត់ស្ទឹង

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឱ្យស់បូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទសហគមន៍**អន្លង់ត្រីស្រែខ្សាច់** នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| **ប្រាំងស្ទឹងអន្លង់ត្រីស្រែខ្សាច់** | ២០ហិកតា | ដាំកូនឈើតាមប្រាំង | ខែធ្នូ ២០១៩ | ខែធ្នូ ២០២០ |
| | | ផ្សព្វផ្សាយការពារប្រាំងស្ទឹងបាក់ | ខែធ្នូ ២០១៩ | ខែធ្នូ ២០២១ |

### គ.៣. ផែនការរៀបចំកន្លែងអភិរក្ស

កន្លែងសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០៣កន្លែង គឺអន្លង់តាំងយូ អន្លង់តាំងគត់ និងអន្លង់សៀមហាយ ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំង០៣កន្លែងនេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ចូលរួមការពារធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ង់ ផ្សព្វផ្សាយ ក្តារខៀនព័ត៌មានបិទផ្សាយបទបញ្ញត្តិផ្សេងៗ សាងសង់រោងយាម សម្រាប់ក្រុមល្បាតបំពេញការងារ និង សម្ភារៈ ផ្សេងទៀត។

**ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖**

| ទីតាំង | ទំហំ ហត | ប្រភេទនៃការអភិរក្ស | សកម្មភាព | ខែ ឆ្នាំ ចាប់ផ្តើម | ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **អន្លង់តាំងយូ** | ០,១២ | | | | |
| **អន្លង់សៀមហាយ** | ០,៤៨ | ត្រីវារីសត្វគ្រប់ប្រភេទ ព្រៃលិចទឹកគ្រប់ប្រភេទ | - ធ្វើស្លាកសញ្ញាអន្លង់អភិរក្សត្រីមេពូជ និងធ្វើបង្គោល<br>- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>- កំណត់ និងបោះបង្គោលព្រំប្រទល់<br>- បោះស្លាកសញ្ញាអភិរក្ស<br>- ទំលាក់គល់ឈើ និងលូស៊ីម៉ង់<br>- ចុះល្បាតការពារកន្លែងអភិរក្ស<br>- សង់រោងយាម | ២០១៩ | ២០២១ |
| **អន្លង់តាំងគត** | ០,៣ | | | | |

## គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹក បានគ្របដណ្តប់លើដែននេសាទសហគមន៍**អន្លង់ត្រីស្រែខ្សាច់** ដែលបានផ្តល់នូវសក្តានុពលនិងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី សត្វល្មូន និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រក និងរស់នៅបង្កកំណើតជាកូន ព្រមទាំងជាប្រភពចំណីផងដែរ។

ផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង

- ថែរក្សា ការពារព្រៃលិចទឹកឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍នេសាទ **អន្លង់ត្រីស្រែខ្សាច់** មានដូចជា៖

| ឈ្មោះ ទីតាំង | ទំហំ ហិត | កូនឈើដែល ត្រូវការពារ | សកម្មភាព | ខែ ឆ្នាំ ចាប់ផ្តើម | ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **តាមច្រាំងស្ទឹងក្បែរដែននេសាទ** | ៩ | ➤ រាំង | • ផ្សព្វផ្សាយពីផលប្រយោជន៍ ព្រៃលិចទឹក | ០៥/២០១៩ | ០៣/២០២០ |
| | | ➤ ផ្តោល | • ដាំកូនឈើ និងដាក់ស្លាកសញ្ញា | ០៦/២០១៩ | ១១/២០១៩ |
| | | ➤ ត្នួរ | • ថែរក្សា និងការពារ | ០៦/២០១៩ | ០៣/២០២០ |
| | | ➤ ប្រកែង | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

## គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ការនេសាទត្រី ការចិញ្ចឹមត្រី ជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគមន៍ **អន្លង់ត្រីស្រែខ្សាច់** ជាទូទៅ ប្រជាពលរដ្ឋ ក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រី ដែលការចិញ្ចឹមត្រីមានដូចជា ត្រីកង្កែប និងត្រីអណ្តែង។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់នៅក្នុងវិស័យជលផលក្នុងការបង្កើនត្រីសាច់ សម្រាប់បរិភោគរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានសម្រាប់នាំចេញទៅទីផ្សារ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

*ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ៣២៥ ប្រក.កសក ស្តីពីការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្តោរ ដែលត្រូវបានទិញពីផ្សារការប្រជាពលរដ្ឋនៅមូលដ្ឋាន។*

ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទ**អន្លង់ត្រីស្រែខ្សាច់** ក្នុងគោលបំណង ៖

- បង្កើនត្រីសាច់សម្រាប់បរិភោគ របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលទទួលបានពីការត្រី
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

**ផែនការរៀបចំអភិវឌ្ឍន៍វារីវប្បកម្មក្នុងកន្លែងនេសាទសហគមន៍ អន្លង់ត្រីស្រែខ្សាច់ ដូចខាងក្រោម៖**

| ប្រភេទ វារីវប្បកម្ម | សកម្មភាព | ចំនួន គ្រួសារ | ប្រភេទកូន ត្រីពូជ | បរិមាណកូន ត្រីពូជ | ខែ/ឆ្នាំ ចាប់ផ្តើម | ខែ/ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីក្នុងស្រះ | - បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- ធ្វើបែប្ញស្សីចិញ្ចឹម<br>- ផ្តល់កូនត្រី<br>- តាមដានត្រួតពិនិត្យ | ២០ | អណ្តែងកូនកាត់ | ១០០០០ក្បាល | ១០/៩/១៩ | ៣០/៩/២០ |
| ចិញ្ចឹមកង្កែបក្នុងស្រះ | | ១០០ | កង្កែប | ៥០០០ក្បាល | ១០/៩/១៩ | |

### ឝ.៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

កម្មការសហគមន៍អន្លង់ត្រីស្រែខ្សាច់ បានដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូល និងចំណាយពីប្រភព ផ្សេងៗ ដូចជាភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ការគាំទ្រពីឃុំ ចំណូលពីក្រុមសន្សំប្រាក់។

| ប្រភពប្រាក់ចំណូល | សកម្មភាព | ឆ្នាំចាប់ផ្ដើម | ឆ្នាំបញ្ចប់ | ចំណូលសរុបរៀល |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលថវិកាពីសមាជិកភាព | ១០/២០១៩ | ១០/២០២០ | ១៥៦.០០០ រៀល |
| ភាគទានប្រចាំឆ្នាំ | ប្រមូលភាគទាន១ដង/១ឆ្នាំ | ១២/២០១៩ | ១២/២០១៩ | ៤៦៨.០០០ រៀល |
| ភាគទានពីអ្នកខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ភាគទានអ្នកនេសាទខាងក្រៅ | ២០១៩ | ២០២០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិក | ២០១៩ | ២០២០ | |
| ភាគទានពីក្រុមសន្សំ | ប្រមូលប្រាក់បដិភាគពីក្រុមសន្សំ | ២០១៩ | ២០២០ | |

### ឝ.៧. ផែនការចុះល្បាតរបស់សហគមន៍នេសាទ

គោលបំណង

- ថែរក្សាការពារកន្លែងអភិរក្សត្រីមេពូជ
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍។

| កម្មវិធីល្បាត | សម្ភារៈល្បាត | ក្រុមល្បាត | សកម្មភាព | ចាប់ផ្ដើម | បញ្ចប់ |
|---|---|---|---|---|---|
| ល្បាត១ខែ ៧ដង | ទូក កាណូត ពិល មុង អង្រឹង អាវភ្លៀង...... | - ក្រុមល្បាត<br>- គណៈកម្មការ | - ត្រួតពិនិត្យតំបន់អភិរក្ស<br>- កន្លែងនេសាទសហគមន៍ | ២០១៩ | ២០២១ |

### ឝ.៨. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅបេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទ អន្លង់ត្រីស្រែខ្សាច់ ត្រូវមានចំណេះដឹង ដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើស ជាគណៈកម្មការ បានប្រើនីតិវិធី ដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាក់ស្តែងគណៈកម្មការសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយ ត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាព គណៈកម្មការសហគមន៍នេសាទ មានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនង ជាមួយដៃគូអភិវឌ្ឍន៍ និងការៀប ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។

| ផែនការ | ប្រធានបទ/ជំនាញ | អ្នកទទួលខុសត្រូវ | ពេលវេលា | ថវិកា |
|---|---|---|---|---|
| ការពង្រឹងសមត្ថភាព | កំណត់ហេតុនិងរបាយការណ៍ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | ១,៤០០,០០០៛ |
| | សេរលិខិតរដ្ឋបាល | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| | រៀបចំទុកដាក់ឯកសារ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| ការងារគ្រប់គ្រង | របៀបកត់ត្រាប្រចាំថ្ងៃ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | ១,៤០០,០០០៛ |
| | ការគ្រប់គ្រងថវិកា | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| | ការដោះស្រាយទំនាស់ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | ១,៤០០,០០០៛ |
| | សរសេរ សំណើសុំថវិកា | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| | រៀបចំបណ្ដាញសហគមន៍ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | ១,៤០០,០០០៛ |
| | សិក្សាផ្លាស់ប្ដូរបទពិសោធន៍ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | |
| បច្ចេកទេស | ដាំបន្លែ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | [illegible] |
| បច្ចេកទេស | ចិញ្ចឹមត្រី មាន់ ទា ជ្រូក | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | [illegible] |

### គ.៩. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្នធនធានជលផលក្នុងសហគមន៍នេសាទ អន្លង់ត្រីស្រែខ្សាច់ កំពុងទទួលរងនូវការគំរាមកំហែងពីអ្នក ខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានា ការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះតម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឲ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួម ចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។

ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍។

**ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធមានដូចក្នុងតារាងខាងក្រោម ៖**

| ប្រធានបទ | អ្នកទទួលខុសត្រូវ | ពេលវេលា | ថវិកា | ផ្សេងៗ |
|---|---|---|---|---|
| លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ៣ដង | ៦០០,០០០៛ | ស្វែងរកជំនួយ |
| សារៈប្រយោជន៍នៃធនធានជលផល | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ៣ដង | ៦០០,០០០៛ | ស្វែងរកជំនួយ |
| កំណត់ព្រំប្រទល់កន្លែងនេសាទ | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ១ដង | ៦០០,០០០៛ | ស្វែងរកជំនួយ |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ១ដង | ៦០០,០០០៛ | ស្វែងរកជំនួយ |
| ច្បាប់ជលផលទាក់ទងនិងសហគមន៍ | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ៣ដង | ១,២០០,០០០៛ | ស្វែងរកជំនួយ |
| សារៈប្រយោជន៍នៃព្រៃលិចទឹក | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ១ដង | ៦០០,០០០៛ | ស្វែងរកជំនួយ |
| ការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | មន្ត្រីជលផលនិងគណៈកម្មការ | មួយឆ្នាំ១ដង | ៦០០,០០០៛ | ស្វែងរកជំនួយ |

### គ.១០.ផែនការសង់ស្នាក់ការ

ពេលបច្ចុប្បន្នសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ពុំទាន់មានស្នាក់ការសម្រាប់គណៈកម្មការសហគមន៍នេសាទ ធ្វើការនៅឡើយទេ ដែលអាចបង្កការលំបាកក្នុងពេលបំពេញការងារគណៈកម្មការសហគមន៍នេសាទក៏ដូចជាការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ។

គណៈកម្មការសហគមន៍នេសាទ អន្លង់ត្រីស្រែខ្សាច់ មានផែនការសាងសង់ស្នាក់ការសហគមន៍មានដូចខាងក្រោម៖

| ប្រភេទសកម្មភាព | ឆ្នាំចាប់ផ្តើម | ឆ្នាំបញ្ចប់ | តម្លៃប៉ាន់ស្មាន(រៀល) | ប្រភពទុន |
|---|---|---|---|---|
| ផែនការសាងសង់ស្នាក់ការ | ២០១៩ | ២០២២ | ២០.០០០.០០០ | - រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន |
| ផែនការទិញទូក | ២០១៩ | ២០២២ | ២០.០០០.០០០ | |
| តុ កៅអី និងទូឯកសារ | ២០១៩ | ២០២២ | ១.០០០.០០០ | |
| **សរុប** | **៤១.០០០.០០០** | | | |

## គ.១១.ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ

សហគមន៍នេសាទ មានសិទ្ធិរៀបចំបណ្តាញសហគមន៍នេសាទក្នុងគោលបំណងចែករំលែកព័ត៌មានបទពិសោធន៍ មេរៀនដែលបានរៀនសូត្រ ក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍន៍សហគមន៍នេសាទ ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ជា ផលប្រយោជន៍រួមរបស់សហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ។

បណ្តាញសហគមន៍នេសាទ គឺជាការចងសម្ព័ន្ធរួមគ្នារវាងសហគមន៍នេសាទ ដែលសម្របសម្រួលដោយសមាជិកដែលបានជ្រើសរើសឆ្លងកាត់ការទទួលខុសត្រូវពីក្រុមគណៈកម្មការសហគមន៍នេសាទ បណ្តាញសហគមន៍នេសាទមានកម្រិតថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ។បណ្តាញសហគមន៍នេសាទនីមួយៗនឹងត្រូវបានបង្កើតឡើង តាមរយៈការបោះឆ្នោតជ្រើសរើសចេញពីប្រធាន គណៈកម្មការសហគមន៍នេសាទពាក់ព័ន្ធដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ។ បណ្តាញសហគមន៍ នេសាទនឹងមានតួនាទីជួយសម្របសម្រួល និងបានការគាំទ្រពីផ្ទបាលជលផល អាជ្ញាធរ មូលដ្ឋាន និងអង្គការដៃគូ។

បណ្តាញសហគមន៍នេសាទក្នុងគោលបំណង៖

- រំលែកព័ត៌មាន និងបទពិសោធន៍ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ
- បង្កើនការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ ។

| សកម្មភាព | បង្ហាញពីលទ្ធផល | ចំនួន | អ្នកទទួលខុសត្រូវ | ថវិកា |
|---|---|---|---|---|
| ប្រជុំបណ្តាញសហគមន៍នេសាទ | លទ្ធផលសម្រេចបាន ឧបសគ្គ ដំណោះស្រាយ ផែនការបន្ត | ១២ដង/៣ឆ្នាំ | គណៈកម្មការ | ៧២០,០០០៛ |
| ប្រជុំប្រចាំខែគណៈកម្មការ | | ៣៦ដង/៣ឆ្នាំ | គណៈកម្មការ | ១,០៨០,០០០៛ |
| ប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | | ៣៦ដង/៣ឆ្នាំ | គណៈកម្មការ | ៣៦០,០០០៛ |
| ប្រជុំជាមួយសមាជិកសហគមន៍ | បង្កើនការយល់ដឹង | ១២ដង/៣ឆ្នាំ | គណៈកម្មការ | ៦០០,០០០៛ |

## គ.១២.ក្រុមសន្សំ

គោលបំណង

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង ។

| ប្រភេទមុខរបរ | សកម្មភាព | ចាប់ផ្តើម | បញ្ចប់ |
|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ បានចំនួន ២ក្រុម ១ក្រុម = ៣០នាក់ | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>- ការរៀបចំក្រុមសន្សំ ការផ្តល់ទុន<br>- បោះឆ្នោតជ្រើសរើសប្រធាន អនុលេខា និងហិរញ្ញិក<br>- បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>- បណ្តុះបណ្តាលក្រុមលើឯកសារផ្សេងៗ និងថវិកា<br>- ប្រជុំក្រុមសន្សំប្រាក់ប្រចាំខែត្រួតពិនិត្យតាមដាន | កុម្ភៈ/២០១៩ | កុម្ភៈ/២០២១ |

## គ.១៣.ផែនការបង្កើតមុខរបរទ្រទ្រង់ជីវភាពសមាជិកសហគមន៍នេសាទ

គោលបំណង

- ដើម្បីបង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- អោយមានមុខរបរចិញ្ចឹមជីវិត
- មានជីវភាពល្អប្រសើរ។

| ប្រភេទពូជ | បច្ចេកទេស | ចំនួន | ចំនួនគ្រួសារ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| ត្រកួន ត្រសក់ ននោង..... | គ្រាប់ពូជសម្ភារៈ | ២០គីឡូ | ២០គ្រួសារ | ៣,០៦០,០០០៛ | ស្វែងរកជំនួញគាំទ្រ |
| មាន់ ទា ជ្រូក............ | សម្ភារៈ | ១០០គីឡូ | ២០គ្រួសារ | ៥,១០០,០០០៛ | ស្វែងរកជំនួញគាំទ្រ |
| **សរុប** | | | **៤០គ្រួសារ** | **៨,១៦០,០០០៛** | |

## គ.១៤.ផែនការកម្មវិធីទឹកស្អាត

គោលបំណង

- កាត់បន្ថយគ្រោះថ្នាក់ដែលបង្កដោយជំងឺផ្សេងៗ
- បង្កើនការយល់ដឹងពីអនាម័យក្នុងការប្រើប្រាស់។

| ទីតាំង | សម្ភារៈ | ចំនួនប្រជាពលរដ្ឋ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|
| វត្តស្រែវាលលិច | បាសាងទឹក ម៉ាស៊ីនបូមទឹក ទុយោទឹក ធុងទឹក រទេះរុញ.. | ៣១៨នាក់ | ២១,២៥០,០០០៛ | ស្វែងរកជំនួញគាំទ្រ |
| ស្រែវាលកើត | | ៦៧៦នាក់ | ២១,២៥០,០០០៛ | ស្វែងរកជំនួញគាំទ្រ |
| **សរុប** | | **៩៩៤នាក់** | **៤២,៥០០,០០០៛** | |

**ឃ.យុទ្ធសាស្ត្រ**

កន្លែងសហគមន៍នេសាទអន្លង់ត្រីស្រែខ្សាច់ ត្រូវបានរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឲ្យការអនុវត្តផែនការទទួល បានជោគជ័យ ហើយយុទ្ធសាស្ត្រទាំងនោះមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តន៍ផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផល ដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជការរៀបចំកន្លែងអភិរក្សព្រៃលិចទឹកកន្លែងអភិរក្សជីវៈចម្រុះការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការ តាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទ ទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អន្លង់ត្រីខាលស្រែខ្វាច់ រយៈពេល០៣ឆ្នាំ ២០១៩ ដល់ ២០២១

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | |
| ✦ ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍ | ✦កាត់បន្ថយទំនាស់ ការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | ៣០០.០០០ | រាជរដ្ឋាភិបាល | ០៣/២០១៩ | ០៥/២០២១ |
| | ✦សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | ៣០០.០០០ | អង្គការដៃគូ | ០៣/២០១៩ | ១២/២០២១ |
| | ✦ប្រជាពលរដ្ឋក្នុងសហគមន៍យល់ដឹងពីការការប្រើប្រាស់ឧបករណ៍ | ៣០០.០០០ | ស្ថាប័នជំនាញ | ០៣/២០១៩ | ១២/២០១៩ |
| ✦ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ✦អ្នកពាក់ពន្ធ នឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ដទៃ | ២០០ ០០០ | ស្ថាប័នជំនាញ | ០៣/២០១៩ | ១២/២០២០ |
| ✦ ត្រួតពិនិត្យ និងតាមដាន | ✦គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | ២០០ ០០០ | គណៈកម្មការ | ០៣/២០១៩ | ១២/២០២០ |
| **២.ផែនការកែលំអដែននេសាទ** | | | | | |
| ✦ ដាំកូនឈើចំនួន២៥០០ដើម តាមច្រាំងស្ទឹង ចំនួន១លើក | - បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃលិចទឹក | ២.០០០.០០០ | រដ្ឋាភិបាល | ០៣/២០១៩ | ០៣/២០២០ |
| | - ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ | ៣០០.០០០ | អង្គការដៃគូ | ០៣/២០១៩ | ០៣/២០២០ |
| | - ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់ | ៣០០.០០០ | បដិភាគរបស់ | ០៣/២០១៩ | ០៣/២០២០ |
| | - ការសិក្សាលើទំហំដែលត្រូវស្តារ | ៣០០.០០០ | សហគមន៍ | ០៣/២០១៩ | ០៣/២០២០ |
| **៣.ផែនការរៀបចំកន្លែងអភិរក្ស** | | | | | |
| ✦ ដាំព្រៃលិចទឹកឡើងវិញចំនួន១៥០០០ដើម | - ចំនួនព្រៃលិចទឹកនិងកើនឡើង | ១.០០០.០០០ | | ០៨/២០១៩ | ១២/២០១៩ |
| ✦ ផ្សព្វផ្សាយពីសារប្រយោជន៍ព្រៃលិចទឹក | - មានផែនទីសំគាល់កន្លែងអភិរក្ស | ២.០០០.០០០ | | ០៣/២០១៩ | ០៧/២០១៩ |
| ✦ ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | - ស្លាកផ្ទាំងប៉ាណូ នឹងត្រូវបានផលិតសម្រាប់ផ្សព្វផ្សាយ | ២.០០០.០០០ | រាជរដ្ឋាភិបាល | ០៣/២០១៩ | ០៧/២០១៩ |
| ✦ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | - ប្រជាជនមានការយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ៥០០.០០០ | អង្គការដៃគូ | ០៣/២០១៩ | ០៧/២០១៩ |
| | -ប្រជាជនយល់ដឹងពីសារៈប្រយោជន៍ការអភិរក្ស និងចូលរួមថែរក្សា | ៥០០.០០០ | ស្ថាប័នជំនាញ | ០៣/២០១៩ | ០៧/២០១៩ |
| | - ត្រីមេពូជ និងសត្វល្មនសំខាន់ៗ ត្រូវបានធ្វើការអភិរក្ស | ៥០០.០០០ | គណៈកម្មការ | ០៣/២០១៩ | ០៧/២០១៩ |
| | - ប្រភេទព្រៃលិចទឹកនឹងត្រូវបានការពារ | ៥០០.០០០ | សហគមន៍ | ០៧/២០១៩ | ១២/២០១៩ |
| | - ប្រជាជនយល់ដឹងពីសារៈប្រយោជន៍ការអភិរក្ស និងចូលរួមថែរក្សា | ៥០០.០០០ | | ០៧/២០១៩ | ១២/២០១៩ |
| ✦ ចុះល្បាតប្រចាំ | - បទល្មើសនឹងថយចុះតាមរយៈការចុះល្បាតរបស់សហគមន៍ | ១.០០០.០០០ | បដិភាគសហ | | ០៣/២០២០ |

| | | | | | |
|---|---|---|---|---|---|
| ***៤.ផែនការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ*** | | | | | |
| ✚ ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក | សមាជិកសហគមន៍យល់ដឹងពីប្រយោជន៍ និងថែរក្សាព្រៃលិចទឹក | ៥០០.០០០ | រាជរដ្ឋាភិបាល | ០៣/២០១៩ | ០៧/២០២០ |
| ✚ ដាំព្រៃលិចទឹកនៅកន្លែងអភិរក្ស | រៀបចំថ្នាលកូនឈើ ពិធីដាំកូនឈើ ដាក់ស្លាកសញ្ញាការពារ ថែរក្សា | ១.០០០.០០០ | ស្ថាប័នជំនាញ | ០៥/២០១៩ | ០៧/២០២០ |
| ✚ ថែរក្សា និងការពារព្រៃលិចទឹក | ដាក់ស្លាកសញ្ញាការពារ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ | ៥០០.០០០ | អង្គការដៃគូ | ០១/២០១៨ | ០១/២០២០ |
| ✚ ចុះល្បាតជាប្រចាំ | សមាជិកសហគមន៍ ចូលរួមទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក | ៥០០.០០០ | គណៈកម្មការ | ០១/២០១៨ | ០១/២០២០ |
| ***៥.ការអភិវឌ្ឍន៍វារីវប្បកម្ម*** | | | | | |
| ✚ ចិញ្ចឹមត្រីនៅក្នុងស្រះ | - គ្រួសារចំនួន ២០គ្រួសារត្រូវបានជ្រើសរើស | ១០០.០០០ | ស្ថាប័នជំនាញ | ០៣/២០១៩ | ០៤/២០១៩ |
| ✚ ចិញ្ចឹមកង្កែបនៅក្នុងស្រះ | - គ្រួសារចំនួន ២០គ្រួសារត្រូវបានជ្រើសរើស | ៥០០.០០០ | អង្គការដៃគូ | ០៤/២០១៩ | ០៦/២០១៩ |
| ✚ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | - សមាជិកស្ម័គ្រចិត្តនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | ១.៥០០.០០០ | បដិភាគ | ០៦/២០១៩ | ០៧/២០១៩ |
| | - ចំនួនកូនត្រីអណ្តែង១.០០០.០០០កូននឹងត្រូវបានផ្តល់ | ៥០០.០០០ | | ០៨/២០១៩ | ០៨/២០១៩ |
| ✚ ត្រួតពិនិត្យតាមដាន | - សមាជិកស្ម័គ្រចិត្ត នឹងធ្វើការត្រួតពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | ៥០០.០០០ | គណៈកម្មការ | ០១/២០១៩ | ០១/២០២១ |
| ***៦.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍*** | | | | | |
| ✚ ភាគទានពីសមាជិកសហគមន៍ | - ប្រមូលភាគទានពីសមាជិកសហគមន៍នេសាទ | ១៥៦.០០០ | រាជរដ្ឋាភិបាល | ០១/២០១៩ | ០១/២០២០ |
| ✚ ភាគទានប្រចាំឆ្នាំ | - ប្រមូលភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ៤៦៨.០០០ | ស្ថាប័នជំនាញ | ០១/២០១៩ | ០១/២០២០ |
| ✚ ភាគទានពីអ្នកនេសាទខាងក្រៅ ១ខែម្តង | - ប្រមូលភាគទានពីអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ៤០០.០០០ | អង្គការដៃគូ | ០១/២០១៩ | ០១/២០២០ |
| ✚ ភាគទានក្រុមសន្សំ ១ខែម្តង | - ប្រមូលបដិភាគពីក្រុមសន្សំ | ៤០០.០០០ | ក្រុមប្រឹក្សាឃុំ | ០១/២០១៩ | ០១/២០២០ |
| ✚ គម្រោងស្នើសុំ ១ឆ្នាំ២ដង | - បដិភាគពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន និងអង្គការដៃគូ | ៤០០.០០០ | គណៈកម្មការ | ០១/២០១៩ | ០១/២០២០ |
| ***៧.ផែនការចុះល្បាត*** | | | | | |
| ✚ ត្រួតពិនិត្យតំបន់អភិរក្ស | - សមាជិកសហគមន៍ស្ម័គ្រចិត្ត | ២០០.០០០ | អង្គការដៃគូ | ០១/២០១៩ | ១២/២០២០ |
| ✚ ក្នុង១ខែ ល្បាត៨ដង | - គណៈកម្មការ និងសមាជិកសហគមន៍ស្ម័គ្រចិត្ត | ២០០.០០០ | សប្បុរសជន | ០១/២០១៩ | ០២/២០១៩ |
| [illegible]ប្រចាំ | - បទល្មើសនឹងថយចុះតាមរយៈការចុះល្បាតរបស់សហគមន៍ | ១០០.០០០ | បដិភាគ<br>វិនិយោគឃុំ<br>ភាគទាន<br>សហគមន៍<br>ស្ថាប័នជំនាញ | ០៥/២០១៩ | ០៥/២០២០ |

| | | | | | |
|---|---|---|---|---|---|
| **៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | | | | | |
| ✦ ការពង្រឹងសមត្ថភាព | កំណត់ហេតុ របាយការណ៍ លិខិតស្នើសុំ និងលិខិតរដ្ឋបាល | ៣០០.00 | រាជរដ្ឋាភិបាល | ០៥/២០១៩ | ០៦/២០២០ |
| | រៀបចំទុកដាក់លិខិតឯកសារ របៀបកត់ត្រាប្រចាំថ្ងៃ | ៣០០.00 | ស្ថាប័នជំនាញ | ០៥/២០១៩ | ០៦/២០២០ |
| ✦ បណ្តុះបណ្តាលការគ្រប់គ្រង | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.00 | អង្គការដៃគូ | ០១/២០១៩ | ០២/២០១៩ |
| | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.00 | សប្បុរសជន | ០១/២០១៩ | ០២/២០១៩ |
| | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ៣០០.00 | បដិភាគ | ០២/២០១៩ | ០២/២០១៩ |
| | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.00 | វិនិយោគឃុំ | ០៣/២០១៩ | ០៣/២០១៩ |
| | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ៣០០.00 | វិភាគទាន | ១២/២០២០ | ១២/២០២០ |
| ✦ បណ្តុះបណ្តាលបច្ចេកទេស | បង្កើនការយល់ដឹង | ៣០០.00 | សហគមន៍ | ០៣/២០១៩ | ០៣/២០១៩ |
| **៩.ផែនការផ្សព្វផ្សាយច្បាប់ផលផល និងលិខិតបទដ្ឋាន** | | | | | |
| ✦ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង នឹងផ្សព្វផ្សាយ | - បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ | ៤០០.០០០ | រាជរដ្ឋាភិបាល | ០២/២០១៩ | ១០/២០២០ |
| ✦ សារៈប្រយោជន៍ធនធានផលផល | - បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ | ៤០០.០០០ | អង្គការដៃគូ | ០៤/២០១៩ | ០៤/២០២០ |
| ✦ សារៈប្រយោជន៍ព្រៃលិចទឹក | - បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ | ៤០០.០០០ | ស្ថាប័នជំនាញ | ១០/២០១៩ | ១២/២០២០ |
| ✦ ផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋាន | - ពីច្បាប់អនុ និងលិខិតបទដ្ឋាន កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | ៤០០.០០០ | បដិភាគ | ០១/២០១៩ | ០១/២០២០ |
| ✦ ការប្រើប្រាស់ឧបករណ៍នេសាទ | - កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | ៤០០.០០០ | វិនិយោគឃុំ | ០៥/២០១៩ | ០៩/២០២០ |
| **១០. ផែនការសាងសង់ស្នាក់ការ** | | | | | |
| ✦ សាងសង់ស្នាក់ការ | - ងាយស្រួលចុះល្បាត និងបង្ក្រាបបទលមើសនេសាទ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល | ១២/២០១៩ | ០៦/២០១៩ |
| ✦ ទិញទូកល្បាត | - ងាយស្រួលចុះល្បាត និងបង្ក្រាបបទលមើសនេសាទ | ២៨.០០០.០០០ | អង្គការដៃគូ | ០៥/២០១៩ | ១២/២០១៩ |
| ✦ តុ កៅអី និងទូឯកសារ | - សម្ភារៈកៅអី និងទូឯកសារ ត្រូវបានបំពាក់ | ២.០០០.០០០ | វិនិយោគឃុំ | ១២/២០១៩ | ០៦/២០២០ |
| **១១.ការពង្រឹងបណ្តាញសហគមន៍នេសាទនិងចូលប្រជុំផ្សេងៗ** | | | | | |
| ✦ ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក | - បណ្តាញសហគមន៍នេសាទថ្នាក់ស្រុកនឹងត្រូវបានរៀបចំប្រជុំ | ២០០.០០០ | រាជរដ្ឋាភិបាល | ២០១៩ | ២០២០ |
| ✦ ប្រជុំបណ្តាញសហគមន៍នេសាទថ្នាក់ខេត្ត | - បណ្តាញសហគមន៍នេសាទថ្នាក់ខេត្តនឹងត្រូវបានរៀបចំប្រជុំ | ៤០០.០០០ | អង្គការដៃគូ | ២០១៩ | ២០២០ |
| ✦ ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | - ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទនឹងត្រូវបានរៀបចំ | ៨០.០០០ | សប្បុរសជន | ២០១៩ | ២០២១ |
| ✦ ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | - គណៈកម្មការសហគមន៍នឹងចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ៨០.០០០ | | ២០១៩ | ២០២១ |

ទំព័រទី ១៨

| | | | | | |
|---|---|---|---|---|---|
| ***១២. ក្រុមសន្សំ*** | | | | | |
| ♣ បង្កើតក្រុមសន្សំ | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>- ការរៀបចំក្រុមសន្សំ ការផ្តល់ទុន<br>- បោះឆ្នោតជ្រើសរើសប្រធាន អនុលេខា និងហិរញ្ញឹក<br>- បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>- បណ្តុះបណ្តាលក្រុមលើឯកសារផ្សេងៗ និងថវិកា<br>- ប្រជុំក្រុមសន្សំប្រាក់ប្រចាំខែត្រួតពិនិត្យតាមដាន | | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០១៩ | ២០២១ |
| ***១៣. ផែនការលើកកម្ពស់ជីវភាពសមាជិកស.ន*** | | | | | |
| គ្រួសារ គ្រួសារ ឈ្មោះ..... | - គ្រាប់ពូជសម្ភារៈ | ២៥០,០០០៛ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ | ២០១៩ | ២០២១ |
| មាន់ ទា ជ្រូក............ | - សម្ភារៈ | ២៥០,០០០៛ | | ២០១៩ | ២០២១ |
| ***១៤.ផែនការកម្មវិធីទឹកស្អាត*** | | | | | |
| វត្តស្រែវាលលិច | - បាសាងទឹក ម៉ាស៊ីនបូមទឹក ទុយោទឹក ធុងទឹក រទេះរុញ.. | ២១,២៥០,០០០៛ | ស្វែងរកជំនួញគាំទ្រ | ២០១៩ | ២០២១ |
| ស្រែវាលកើត | - បាសាងទឹក ម៉ាស៊ីនបូមទឹក ទុយោទឹក ធុងទឹក រទេះរុញ.. | ២១,២៥០,០០០៛ | អង្គការដៃគូ | ២០១៩ | ២០២១ |

# តារាងកម្មវិធីការងារប្រចាំឆ្នាំ ២០១៩-២០២១

| [illegible] | [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១. ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍ | | | | | | | | | | | x | x | | | | | | | | | | | x | x | | | | | | | | | | | x | x |
| ១.២. ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | | | | x | x | x | x | | | | | | | | | x | x | x | x | | | | | | | | | x | x | x | x | | |
| ១.៣. ត្រួតពិនិត្យ និងតាមដាន | | | x | x | x | x | x | x | x | x | x | x | | | x | x | x | x | x | x | x | x | x | x | | | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១ដាំកូនឈើចំនួន២៥០០ដើម ចំនួន១លើក | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | |
| ៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១.ដាំព្រៃលិចទឹកឡើងវិញ ១៥០០០ដើម | | | | | | | | x | x | x | x | x | | | | | | | | x | x | x | x | x | | | | | | | | x | x | x | x | x |
| ៣.២.ផ្សព្វផ្សាយសារប្រយោជន៍ព្រៃលិចទឹក | | | | | | | | | | | | | | | x | x | x | x | x | x | | | | | | | x | x | x | x | x | | | | | |
| ៣.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | | | | | | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | |
| ៣.៤.ផ្សព្វផ្សាយប្រជាពលរដ្ឋពីកន្លែងអភិរក្ស | | | x | x | x | x | x | x | x | x | x | x | | | | x | x | x | x | x | x | x | x | x | | | x | x | x | x | x | x | x | x | x | x |
| ៣.៥. ចុះល្បាតជាប្រចាំ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.១.ផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃលិចទឹក | | | x | x | x | x | x | | | | | | | | x | x | x | x | x | | | | | | | | | | | | | | | | | |
| ៤.២.[illegible]លិចទឹកនៅកន្លែងអភិរក្ស | | | | | | | | | | | | | | | | | x | x | x | x | x | x | x | x | | | | | x | x | x | x | x | x | x | x |
| ៤.៣.[illegible]ការពារព្រៃលិចទឹក | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៤.៤.ចុះល្បាតជាប្រចាំ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៥.ការអភិវឌ្ឍសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥.១. ចិញ្ចឹមត្រីនៅក្នុងស្រះ | x | | x | x | | | | | | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៥.២. ចិញ្ចឹមកង្កែបនៅក្នុងស្រះ | | | | | x | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.៣. បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | | | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.៤. ត្រួតពិនិត្យ និងតាមដាន | | | | | | | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៦.ការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.១. ភាគទានពីសមាជិកសហគមន៍ | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | |
| ៦.២. ភាគទានប្រចាំឆ្នាំ | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x |
| ៦.៣. ភាគទានអ្នកនេសាទខាងក្រៅ ១ខែម្តង | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៦.៤. ភាគទានក្រុមសន្សំ ១ខែម្តង | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៦.៥. គម្រោងស្នើសុំ ១ឆ្នាំ២ដង | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x |
| ៧.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១. ល្បាត ១ខែ ៤ដង | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៨.ការពង្រឹងសមត្ថភាពគណៈកម្មការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.១. ការពង្រឹងសមត្ថភាព | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | | | | | | | |
| ៨.២. បណ្តុះបណ្តាលការគ្រប់គ្រង | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | |
| ៨.៣. បណ្តុះបណ្តាលបច្ចេកទេស | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | |
| ៨.៤. ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x |
| ៩.ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋាន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.១. ...ផ្ទៃក្នុង នឹងផ្សព្វផ្សាយ | | x | | | | | | | | x | | | | x | | | | | | | | x | | | | x | | | | | | | | x | | |
| ៩.២. ...ផ្ទានជលផល | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | |
| ៩.៣. ...ចទឹក | | | | | | | | | | x | x | x | | | | | | | | | | x | x | x | | | | | | | | | | x | x | x |
| ៩.៤. ផ្សព្វផ្សាយ... នឹងលិខិតបទដ្ឋាន | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៩.៥.ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | x | x | x | x | x | | | | | | | | x | x | x | x | x | | | | | | | x | x | x | x | x | | | | |
| ១០.ផែនការសាងសង់ស្នាក់ការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.១.សាង់សង់ស្នាក់ការ | | | | | | | | | | | | | x | x | x | x | x | | | | | | | | | | | | | | | | | | | |
| ១០.២.ទិញទូកល្បាត | | | | | | | | | | | | | | | | | x | | | | | | | | | | | | | | | | | | | |
| ១០.៣.តុ កៅអី និងទូឯកសារ | | | | | | | | | | | | | | | | | | | | | | | | x | | | | | | | | | | | | |
| ១១.ការពង្រឹងបណ្ដាញសហគមន៍នេសាទ | | | | | | | | | | | | x | x | x | x | x | | | | | | | | x | x | x | x | x | | | | | | | | |
| ១១.១.ប្រជុំបណ្ដាញសហគមន៍នេសាទថ្នាក់ស្រុក | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x |
| ១១.២.ប្រជុំបណ្ដាញសហគមន៍នេសាទថ្នាក់ខេត្ត | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x |
| ១១.៣.ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ១១.៤.ប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ១២.ក្រុមសន្សំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២.១ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍ | | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | |
| ១២.២.ការរៀបចំក្រុមសន្សំ ការផ្ដល់ទុន | | | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | |
| ១២.៣.បោះឆ្នោតរើសប្រធាន អនុលេខា ហិរញ្ញិក | | | | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | |
| ១២.៤.បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | | | | | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | |
| ១២.៥.បណ្ដុះបណ្ដាលក្រុម ថវិកា | | | | | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | |
| ១២.៦ប្រជុំក្រុមសន្សំប្រចាំខែត្រួតពិនិត្យតាមដាន | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ១៣.ផែនការបង្កើមុខរបរទ្រទ្រង់ជីវភាពសមា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| គ្រក្នួន គ្រសក់ ននោង..... | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | x | |
| មាន [illegible] | | | | | | | | | | | | | | x | x | | | | | | | | | | | x | x | | | | | | | | | |
| ១៤.ផែនការ[illegible]ទឹកស្អាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| [illegible] ម៉ាស៊ីនបូមទឹក ទុយោទឹក [illegible] | | | | | | | | | | | | | x | x | x | x | x | | | | | | | | x | x | x | x | | | | | | | | |

សូមគោរពជូន

លោកមេឃុំជងកាំបិត

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

........, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៩

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ: ០៩៤

---

លេខ: ១៦៤

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលសណ្ដាន់

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ជងកាំបិត, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៩

**មេឃុំជងកាំបិត**

ឈុន_ម៉េង

---

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សណ្ដាន់, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៩

**នាយសង្កាត់រដ្ឋបាលជលផលសណ្ដាន់**

---

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ប្រាសាទសំបូរ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៩

**នាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ**

---

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កំពង់ធំ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

ប៉ែន_វណ្ណរិទ្ធ

---

លេខ: ១៣០៤........

បានឃើញនិងគោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កំពង់ធំ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៩

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ**

ជឹម វណ្ណធីរ

---

លេខ: ........

បានឃើញនិងឯកភាព

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន